# មេរៀនទី ១២៩:ស្ទេផានឈរមាំដើម្បីព្រះ

## កិច្ចការ ៦:៨-៧:៦០

**គោលបំណង៖** យើងបានថ្វាយកិត្តិនាមដល់ទ្រង់នៅពេលដែលយើងឈរមាំជាមួយនឹងទ្រង់។

**ខគម្ពីរចងចាំ៖ កិច្ចការ ៧:៥៥** *"តែដែលគាត់បានពេញជាព្រះវិញ្ញាណបរិសុទ្ធ នោះក៏សំឡឹងមើលទៅលើ មើយ ឃើញសិរីល្អនៃព្រះ និងព្រះយេស៊ូវឈរនៅខាងព្រះហស្តស្តាំ។"*

**ការថ្វាយបង្គំសំរាប់គ្រូ៖ (សូមអាន ហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**

ទំនាក់ទំនងកាន់តែរីកចម្រើនជាមួយព្រះយេស៊ូវបង្កើតនូវសេចក្តីជំនឿ និងភាពក្លាហាននៅក្នុងចិត្តនឹងជីវិតរបស់គ្រីស្ទបរិស័ទ។ ភាពក្លាហាននេះអនុញ្ញាតឱ្យយើងនិយាយការពិត នៅពេលប្រឈមមុខនឹងគ្រោះថ្នាក់។ ការនិយាយការពិតពីព្រះយេស៊ូវនឹងមិនបានធ្វើឱ្យអ្នកស្លាប់នោះឡើយ ប៉ុន្តែមានគ្រីស្ទបរិស័ទជាច្រើនបានស្លាប់ ហើយក៏មានអ្នកជឿជាច្រើនទៀតបានរងទុក្ខរហូតដល់ស្លាប់ ដោយព្រោះតែពួកគេបានព្យាយាមនិយាយពីសេចក្តីជំនឿ និងសេចក្តីពិត។ សូមចំណាយពេលអរព្រះគុណព្រះ ចំពោះបុរសនិងស្ត្រីណាដែលមានរឿងដូចជាស្ទេផាន ដែលពួកគេបានលះបង់ជីវិតរបស់ពួកគេសម្រាប់ប្រយោជន៍នៃដំណឹងល្អ។ តើអ្នកអាចថ្លែងអំណរគុណចំពោះពួកគេបានដោយរបៀបណានៅក្នុងជីវិតរបស់អ្នក? អ្នកបានចូលរួមធ្វើកិច្ចការជាមួយនឹងពួកគេទាំងនោះ នៅរាល់ពេលដែលអ្នកនិយាយពីសេចក្តីពិតអំពីជីវិត និងការងាររបស់ព្រះយេស៊ូវគ្រីស្ទ។

**ចំរៀង៖** ១.គឺជាការល្អដែលសរសើរព្រះ ២.ខ្ញុំបានសម្រេចចិត្ត ៣.ចូរមានកម្លាំងនិងមានចិត្តក្លាហានចុះ

**១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបើក)*

**២. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**៣. ល្បែងកំសាន្ត «អៀវគ្នាទាត់បាល់»**

**សម្ភារៈដែលត្រូវការ៖** បាល់ ២



១. ចែកកុមារជា ២ក្រុម ហើយឲ្យពួកគេចាប់ដៃគូរពីរៗនាក់

២. ក្រុមនីមួយៗត្រូវយកបាល់ម្នាក់មួយ ហើយឲ្យពួកគេអៀវគ្នា

៣. នៅពេលដែលគ្រូរាប់ ១ ២ ៣ គូរទីមួយត្រូវទាត់បាល់ (ដោយអៀវដៃគូររបស់ខ្លួន) ទៅឲ្យដល់ចុងម្ខាងនៃថ្នាក់រៀន ហើយរត់ត្រឡប់មកកាន់ទីចាប់ផ្តើមវិញ។

៤. នៅពេលដែលគូរទី១ ត្រឡប់មកដល់ទីវិញ គូរទីពីរត្រូវបន្តទាត់បាល់ និងអៀវគ្នាផង

៥. ក្រុមណាដែលអាចលេងបានគ្រប់គ្នាមុន នឹងឈ្នះល្បែងនេះ

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា បើទោះបីជាដៃគូររបស់ពួកគេមានការធ្ងន់ក្នុងការអៀវដៃគូររបស់ខ្លួនក៏ដោយ តែពួកគេនៅតែបន្តអៀវដៃគូររហូតដល់ចប់ល្បែងនេះ។ ក៏ដូចគ្នានេះដែរពួកយើងត្រូវតែឈរមាំសម្រាប់ព្រះយេស៊ូវរហូតដល់ថ្ងៃស្លាប់។

## ៤. ការណែនាំមេរៀន

តើអ្នកធ្លាប់មានការភ័យខ្លាច នៅពេលដែលនិយាយប្រាប់អ្នកណាម្នាក់ពីព្រះយេស៊ូវប៉ុន្តែអ្នកនៅតែធ្វើវាឬទេ? តើមានអ្នកខឹងនឹងអ្នកនៅពេលដែលអ្នកជឿព្រះ ឬធ្វើអ្វីដែលជារឿងត្រឹមត្រូវដែរឬទេ? តើអ្នកមានអារម្មណ៍ភ័យខ្លាចក្នុងការនិយាយពីសេចក្តីពិតអំពីព្រះទៅកាន់នរណាម្នាក់ដែរឬទេ? ថ្ងៃនេះយើងនឹងរៀនពីបុរសម្នាក់ដែលមិនខ្លាចក្នុងការនិយាយពីព្រះយេស៊ូវ បើទោះបីជាគាត់ត្រូវបានគេគម្រាមសម្លាប់ក៏ដោយ!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

បន្ទាប់ពីព្រះយេស៊ូវបានសុគត និងរស់ឡើងវិញមក អ្នកដែលដើរតាមទ្រង់បាននៅតែបន្តនិយាយពីទ្រង់ពីអ្វីដែលមាននៅក្នុងចិត្តរបស់គេនៅគ្រប់កន្លែងដែលគេបានទៅ។ នៅក្នុងចំណោមអ្នកដែលជឿនោះមានបុរសម្នាក់ឈ្មោះស្ទេផាន។ គាត់ជាមនុស្សដែលមានសេចក្តីជំនឿ និងពេញដោយព្រះវិញ្ញាណបរិសុទ្ធ។ គាត់បានធ្វើនូវរឿងអស្ចារ្យជាច្រើនឱ្យហ្វូងមនុស្សបានឃើញ។

មនុស្សជាច្រើនមិនជឿថាព្រះយេស៊ូវគឺជាព្រះរាជបុត្រានៃព្រះនោះទេ។ គេក៏មិនចូលចិត្តនូវអ្វីដែលស្ទេផានបាននិយាយផងដែរ។ ពួកគេបាននិយាយកុហកពីលោកស្ទេផាន ហើយធ្វើឲ្យមនុស្សជាច្រើនស្អប់គាត់។ គេបានចាប់ស្ទេផានទៅកាត់ទោស។ ទោះបីជានៅពេលវេលាចុងក្រោយនៃជីវិតរបស់គាត់ក៏ដោយ ក៏ស្ទេផាននៅតែព្យាយាមធ្វើយ៉ាងណាឱ្យមនុស្សជឿលើព្រះយេស៊ូវដែរ។ រឿងនេះធ្វើឱ្យមនុស្សកាន់តែខឹងនឹងស្ទេផាន ដោយពួកគេបានទាញគាត់ចេញទៅខាងក្រៅទីក្រុង រួចចោលគាត់នឹងដុំថ្មសម្លាប់។ ក្នុងពេលដែលហ្វូងមនុស្សកំពុងតែចោលគាត់នឹងថ្មនោះ ស្ទេផានបានអធិស្ឋានថា "ឱព្រះអម្ចាស់យេស៊ូវអើយ សូមទទួលវិញ្ញាណទូលបង្គំផង" គាត់បានលុតជង្គង់ចុះរួចនិយាយថា "ឱព្រះអម្ចាស់អើយ សូមកុំរាប់បាបនេះដល់គេឡើយ" រួចគាត់ក៏ស្លាប់ទៅ។

ស្ទេផានគឺជាមនុស្សទីមួយនិងជាមនុស្សម្នាក់ដែលស៊ូស្លាប់ដោយសារតែសេចក្តីជំនឿរបស់គាត់។ គាត់ត្រូវបានគេចោលនឹងដុំថ្ម ពីព្រោះតែគាត់បានចែកចាយពីព្រះយេស៊ូវ។ នៅពេលដែលគាត់ឈរនៅខាងព្រះគឺមានន័យថាគាត់បានថ្វាយនូវកិត្តិនាមដល់ទ្រង់។ មនុស្សជាច្រើនបានជឿដល់ព្រះយេស៊ូវ ដោយព្រោះតែទង្វើរបស់ស្ទេផាន។

ព្រះវិញ្ញាណបរិសុទ្ធនិងព្រះយេស៊ូវបានគង់នៅជាមួយនឹងស្ទេផាន នៅពេលដែលគាត់បានឈរមាំជាមួយព្រះ បើទោះបីជាលទ្ធផលចុងក្រោយគាត់ត្រូវស្លាប់ក៏ដោយ។ មានមនុស្សជាច្រើននៅមិនទាន់ប្រឈមមុខនឹងសេចក្តីស្លាប់នៅពេលដែលយើងនិយាយពីព្រះយេស៊ូវនៅឡើយទេ ប៉ុន្តែព្រះបានសន្យាថាទ្រង់គង់ជាមួយយើងមិនថាយើងស្ថិតនៅក្នុងស្ថានភាពបែបណានោះទេ។ មិនថានៅពេលយើងនិយាយប្រាប់មនុស្សថាព្រះយេស៊ូវស្រឡាញ់ពួកគេ ឬក៏ប្រាប់មិត្តភក្តិយើងថាកុំឱ្យលួចរបស់អ្វីមួយក៏ដោយ ប៉ុន្តែសូមចាំថាការឈរមាំជាមួយព្រះគឺយើងបានថ្វាយកិត្តិនាមទៅដល់ទ្រង់។

ជាថ្មីម្តងទៀត ការឈរមាំជាមួយព្រះគឺមានន័យថា គឺយើងធ្វើតែរឿងអ្វីដែលត្រឹមត្រូវទោះបីជាអ្នកដទៃមិនឯកភាពជាមួយយើងក៏ដោយ។ គឺមានន័យថានិយាយសេចក្តីពិតពីព្រះ នៅពេលដែលអ្នកដទៃនិយាយមិនពិតពីទ្រង់។ ហើយគឺមានន័យថា ប្រាប់អ្នកដទៃពីព្រះយេស៊ូវបើទោះបីជាគេគិតថាវាជារឿងមិនពិតក៏ដោយ។ ព្រះយេស៊ូវគឺជាគម្រូដ៏ល្អឥតខ្ចោះម្នាក់ដែលបានឈរមាំជាមួយនឹងព្រះជាម្ចាស់។ ព្រះយេស៊ូវទ្រង់មានបន្ទូលអំពីសេចក្តីពិតពីព្រះ

បើទោះបីជាមានមនុស្សជាច្រើនបានស្អប់ទ្រង់ក៏ដោយ។ ទ្រង់បានស្ដាប់បង្គាប់ព្រះនៅគ្រប់កាលៈទេសៈទាំងអស់ ទោះបីជាព្រះអង្គត្រូវសុគតនៅលើឈើឆ្កាងក៏ដោយ។

ដោយព្រោះតែមានទ្រង់ជាគម្រូរបស់យើង យើងក៏អាចឈរមាំដើម្បីព្រះជាម្ចាស់ដូចគ្នា។ យើងអាចធ្វើដូចជាស្ទេផាននិងប្រាប់មនុស្សគ្រប់គ្នា "ព្រះយេស៊ូវស្រឡាញ់អ្នក!" យើងក៏អាចធ្វើដូចជាស្ទេផាន និងរៀនអំពីរឿងរ៉ាវនៅក្នុងព្រះគម្ពីរ។ យើងអាចធ្វើដូចជាស្ទេផាន ដោយការស្រឡាញ់ព្រះជាម្ចាស់ឱ្យអស់ពីចិត្ត ដោយការស្រឡាញ់មនុស្សដែលនៅជុំវិញខ្លួនយើង បើទោះបីជាអ្នកនោះធ្វើមិនល្អដាក់យើងក៏ដោយ។ នៅគ្រប់ពេលដែលយើងធ្វើដូចនេះ គឺយើងបានឈរមាំដើម្បីព្រះជាម្ចាស់របស់យើង និងថ្វាយកិត្តិនាមដល់ទ្រង់ផងដែរ។

**៦. សំនួរពិភាក្សា**

១. តើស្ទេផានក្រោកឈរដើម្បីព្រះដោយរបៀបណា? *គាត់ស្រឡាញ់ព្រះ ស្រឡាញ់មនុស្ស ធ្វើការអស្ចារ្យ ប្រាប់មនុស្សពីព្រះយេស៊ូវ និងបានអត់ទោសដល់អ្នកដែលបានសម្លាប់គាត់ទៀតផង*

២. តើមានរឿងអ្វីកើតឡើងចំពោះគាត់? *មនុស្សមិនជឿថាព្រះយេស៊ូវគឺជាព្រះ ហើយបានចោលគាត់នឹងដុំថ្ម*

៣. តើមានហេតុផលអ្វីខ្លះដែលធ្វើឱ្យមនុស្សមិននៅឈរមាំជាមួយនឹងព្រះ? *សូមឱ្យកុមារឆ្លើយ*

៤. តើអ្នកធ្វើយ៉ាងដូចម្ដេចដើម្បីឈរមាំជាមួយនឹងព្រះ? *សូមឱ្យកុមារឆ្លើយ*

**៧. ល្បែងកំសាន្ត «ឈរមាំដើម្បីព្រះ»**



**សម្ភារៈដែលត្រូវការ៖** កែវក្រដាស និងតុ

១. ចែកកុមារជា២ក្រុម ហើយឲ្យពួកគេឈរជាជួរតាមក្រុម

២. ឲ្យកែវក្រដាសទៅកុមារម្នាក់១ នៅពេលដែលគ្រូរាប់ ១ ២ ៣ កុមារទី១មកពីក្រុមទាំងពីរត្រូវរត់យកកែវទៅដាក់នៅលើតុ។

៣. កុមារបន្ទាប់ត្រូវរត់ទៅកាន់តុហើយដាក់កែវរបស់គេពីលើកែវរបស់សមាជិកក្រុមខ្លួន

៤. លេងល្បែងនេះរហូតដល់ក្រុមណាមួយអាចដាក់កែវក្រដាសនោះលើគ្នាបាន៦កែវ។

៥. ប្រសិនបើកែវទាំងនោះដួលពួកគេត្រូវចាប់ផ្ដើមសារជាថ្មី។

៦. បន្ទាប់ពីលេងល្បែងនេះចប់សូមពន្យល់កុមារថា ពេលខ្លះយើងគឺមានការពិបាកក្នុងការឈរមាំសម្រាប់ ព្រះយេស៊ូវ វាក៏ពិបាកដូចជាការដែលធ្វើឲ្យកែវឈរមាំអីចឹងដែរ។ ប៉ុន្តែយើងត្រូវតែឈរមាំសម្រាប់ព្រះយេស៊ូវជានិច្ចពីព្រោះទ្រង់ជាស្ដេចដ៏មានព្រះចេស្ដារបស់យើង!

**៨. ខគម្ពីរចងចាំ** កិច្ចការ ៧:៥៥

**៩. ហត្ថកម្ម** សូមផាត់ពណ៌រូបភាព «ស្ទេផានបានឈរមាំជាមួយនឹងព្រះ»

**១០. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១១. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*

# ស្ទេផានបានឈរមាំជាមួយនឹងព្រះ



សូមសរសេរខគម្ពីរចងចាំ: ______________________________

______________________________________________

______________________________________________

______________________________________________